**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៥៨៣៨
ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦
ជំនុំជម្រះលេខ:១៧១
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧
សាលក្រមព្រហ្មទណ្ឌ
លេខៈ ៨៥ក្រ៩-អ-
ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការ នៃសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted]ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក[redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៥៨៣៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ ដែលមានជនជាប់ចោទៈ
១-ឈ្មោះ [redacted]ដារ៉ែត ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មកររោងចក្រ
ទីកន្លែងកំណើតនៅខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ននៅ[redacted] ខណ្ឌមាន
ជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] -រ- ម្តាយឈ្មោះ[redacted] -ស- នៅរស់ ជាអនីតិជន
ទោសពីមុនគ្មាន។
ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៧៣៧៦-ឆ- ជ.យ.ជ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើប
សួរសាលាដំបូងរាជធានីភ្នំពេញ។
២-ឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរធ្វើការរោងចក្រ
ទីកន្លែងកំណើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ននៅ[redacted] ខណ្ឌ
មានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]-ស- ម្តាយឈ្មោះ[redacted] -រ- នៅរស់ ជានីតិជន ទោស
ពីមុន ធ្លាប់ជាប់ពន្ធនាគាររយៈពេល០៨ខែ ពីបទប៉ុនប៉ងលួច។
ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៧៣៧៥-ឆ- ជ.យ.ជ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើប
សួរសាលាដំបូងរាជធានីភ្នំពេញ។
ជាប់ចោទពីបទៈ លួច ប្រព្រឹត្តនៅចំណុចមុខផ្សារទំនើបឡាក់គី ផ្លូវព្រះសីហនុ សង្កាត់បឹងកេង
កង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមាន
ចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។
មេធាវី[redacted]ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ែត។
-បានឃើញ របាយការណ៍សរុបលេខ១៨៣/២០១៦ របក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ របស់
ការិយាល័យបទល្មើសព្រហ្មទណ្ឌ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ។
-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៣៨១៨ អ.យ.ឌ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ
២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៣៧៣៩ អ.យ.ឌ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ របស់
តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៩៥-ឆ- ជ.ជ ចុះថ្ងៃទី០៩ ខែមករា
ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។



Scanned by CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង២១ និង៣០នាទី នៅចំណុចមុខផ្សារទំនើបឡាក់គី ផ្លូវសីហនុ សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ ពេលនោះឈ្មោះ [redacted] ដាវិត និងឈ្មោះ [redacted] ណារិន បានជិះម៉ូតូ០១គ្រឿងម៉ាកស៊ុយស៊ុលគីនិច ពណ៌ស ក្នុងគោលបំណងរកឆក់ ស្រាប់តែប្រទះឃើញជនរងគ្រោះជិះម៉ូតូកង់បី ដោយមានដាក់កាបូបនៅលើភ្លៅ ក៏ធ្វើសកម្មភាពឆក់ពីជនរងគ្រោះបានសម្រេច ហើយនាំគ្នាជិះម៉ូតូគេចខ្លួន ពេលនោះក៏មានប្រជាពលរដ្ឋស្រែកថាចោរៗ លុះគេចខ្លួនមកដល់ចំណុចមុខខាហ៊ាអូខេ ហ្សង់អេលីហ្សេ ឈ្មោះ [redacted] ដាវិត និងឈ្មោះ [redacted] ណារិន ក៏ជិះម៉ូតូបុកគូទឡានដែលគេចតទុកចោលបណ្តាលឲ្យដួលបន្ទាប់មកក៏ត្រូវបានប្រជាពលរដ្ឋចាប់បានប្រគល់ឲ្យសមត្ថកិច្ច។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] ដាវិត បានឆ្លើយថា កាលពីថ្ងៃកើតហេតុ ខ្លួនបានបបួលឈ្មោះ ណារិន ដើរលេងកោះពេជ្រ។ ខ្លួនជាអ្នកបើកម៉ូតូឌុបឈ្មោះ ណារិន ដោយម៉ូតូនោះជាម៉ូតូរបស់ខ្លួនម៉ាកនិច។ ខ្លួន និងឈ្មោះ ណារិន បានបបួលគ្នាជិះម៉ូតូឆក់កាបូបគេ។ ពេលនោះពួកខ្លួនឃើញមនុស្សស្រីម្នាក់ជិះម៉ូតូកង់បី ហើយឈ្មោះ ណារិន ឲ្យខ្លួនជិះម៉ូតូទៅអែប ហើយឈ្មោះ ណារិន ជាអ្នកឆក់កាបូបរបស់គេ តែឆក់មិនបានទេក៏ដួលម៉ូតូ ពួកខ្លួនរត់បានមួយភ្លែត ក៏ត្រូវប្រជាជនចាប់ខ្លួនបានប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ សមត្ថកិច្ចដកហូតម៉ូតូមួយគ្រឿង ទូរស័ព្ទដៃមួយគ្រឿង និងលុយចំនួន១៥ដុល្លារអាមេរិក។ ខ្លួនទើបតែឆក់លើកទី១។ ពេលគេចាប់ខ្លួនបានហើយ ខ្លួនមានការស្តាយក្រោយណាស់ ហើយពេលបានចេញទៅវិញ ខ្លួននឹងកែប្រែខ្លួនឈប់ប្រព្រឹត្តខុសទៀតហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ណារិនបានឆ្លើយថា ខ្លួនពិតជាបានឆក់កាបូបគេមែន។ មុនពេលកើតហេតុឈ្មោះ ដាវិត បបួលខ្លួនទៅក្លឹប ហើយខ្លួនអត់មានលុយ ឈ្មោះ ដាវិត ក៏បបួលខ្លួនទៅរកលុយ។ ពេលនោះពួកខ្លួនជិះម៉ូតូតាមផ្លូវ ឃើញនារីម្នាក់ជិះម៉ូតូកង់បី ដោយដាក់កាបូបនៅលើភ្លៅ ហើយខ្លួនឲ្យឈ្មោះ ដាវិត ជិះម៉ូតូទៅអែប បន្ទាប់មកខ្លួនក៏ឆក់កាបូបនោះបាន តែមានរថយន្តដេញបុកពីក្រោយ តែអត់ត្រូវ ក៏បណ្តាលឲ្យដួលម៉ូតូ ហើយមានប្រជាជនមកចាប់ពួកខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ កាបូបនោះត្រូវម្ចាស់ដើមយកវិញហើយ។ ខ្លួនស្គាល់ឈ្មោះ ដាវិត នៅតាមក្លឹប មិនដឹងអាយុរបស់វាប៉ុន្មានទេ។ ពេលនោះខ្លួនជាអ្នកឆក់។ ឈ្មោះ ដាវិត ជាអ្នកបើកម៉ូតូ ដោយសារខ្លួនអត់ចេះជិះម៉ូតូទេ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យកលេខ២០៦ រ.វ.ត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ វត្ថុតាងរួមមាន៖ ១-ម៉ូតូចំនួន០១គ្រឿង ម៉ាកនិច ពណ៌ស ស្លាកលេខភ្នំពេញ ១FK-៩៨៩៧ ២-ទូរស័ព្ទម៉ាកណូគារចុចពិល០១គ្រឿង។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានសួរដេញដោល ឃើញថាជនជាប់ចោទទាំងពីរនាក់នេះ បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះប្រាកដមែន។ ឃើញថា ចម្លើយនេះមានភាពស៊ីសង្វាក់គ្នា ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ និងសុំឲ្យតុលាការសម្រេចតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ដាវិត បានឆ្លើយសារភាព និងបានដឹងពីកំហុសរបស់ខ្លួនហើយថា ការប្រព្រឹត្តនេះគឺមិនត្រឹមត្រូវទេ ហើយកូនក្តីខ្លួនជាអនីតិជន និងជាកូនកំព្រាដែលរស់នៅជាមួយជីដូន ពុំទទួលបានការអប់រំបានត្រឹមត្រូវនោះទេ។ ដូចនេះ សំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួនផង ដើម្បីឲ្យកូនក្តីខ្លួនមានឱកាសចូលរៀនបន្ត និងមានអនាគតល្អឡើងវិញ។

-ជនជាប់ចោទឈ្មោះ [redacted] ដាវិត និយាយសំដីចុងក្រោយថា: សុំលោកចៅក្រមមេត្តាបន្ធូរបន្ថយទោសឲ្យរូបខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ណារិន និយាយសំដីចុងក្រោយថា: សុំលោកចៅក្រមមេត្តាបន្ធូរបន្ថយទោសឲ្យរូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទម្នាក់ៗ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យ



Scanned by CamScanner

ជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទម្នាក់ៗ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងត្រឹមត្រូវហើយ

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង២១ និង៣០នាទី នៅចំណុចមុខផ្សារទំនើបឡាក់គី ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានករណីលួច កើតឡើងបង្កដោយឈ្មោះ [redacted] ដារីត និងឈ្មោះ [redacted] ណារិន បានជិះម៉ូតូមួយគ្រឿងម៉ាកស៊ុយស៊ុលគីនិច ពណ៌សធ្វើសកម្មភាពឆក់កាបូបពីជនរងគ្រោះប្រាកដមែន។

២-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៩៥-ឆ-ដ.ជ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ដារីត ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ [redacted] ណារិន ភេទប្រុស អាយុ២៦ឆ្នាំ មកជំនុំជម្រះពីបទលួច ប្រព្រឹត្តនៅនៅនៅចំណុចមុខផ្សារទំនើបឡាក់គី ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដារីត បានឆ្លើយសារភាពថា ខ្លួនពិតជាបានបើកម៉ូតូរបស់ខ្លួនម៉ាកនិច ឌុបឈ្មោះ [redacted] ណារិន ទៅឆក់កាបូបជនរងគ្រោះដែលកំពុងជិះលើម៉ូតូកង់បីប្រាកដមែន។ ចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ណារិន ដែលបានឆ្លើយសារភាពថា ខ្លួនពិតជាបានឆក់កាបូបគេមែន ដោយមុនពេលកើតហេតុឈ្មោះ ដារីត បបួលខ្លួនទៅក្លឹប ហើយខ្លួនអត់មានលុយ ឈ្មោះ ដារីត ក៏បបួលខ្លួនទៅរកលុយ។ ពេលនោះពួកខ្លួនជិះម៉ូតូតាមផ្លូវ ឃើញនារីម្នាក់ជិះម៉ូតូកង់បី ដោយដាក់កាបូបនៅលើភ្លៅ ហើយខ្លួនឲ្យឈ្មោះ ដារីត ជិះម៉ូតូទៅអែបបន្ទាប់មកខ្លួនក៏ឆក់កាបូបនោះបាន តែមានរថយន្តដេញបុកពីក្រោយ តែអត់ត្រូវ ក៏បណ្តាលឲ្យដួលម៉ូតូ ហើយមានប្រជាជនមកចាប់ពួកខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ កាបូបនោះត្រូវម្ចាស់ដើមយកវិញហើយ។

៤-ជនជាប់ចោទឈ្មោះ [redacted] ដារីត ជាអនីតិជន ចំណែកជនជាប់ចោទឈ្មោះ [redacted] ណារិន ជានីតិជន ហើយជនជាប់ចោទទាំងពីរនាក់នេះ សុទ្ធតែមានស្មារតីគ្រប់គ្រាន់ និងនីតិសម្បទាបរិបូរណ៍ ហើយពុំមានសញ្ញាណាមួយដែលនាំឲ្យមានមន្ទិលសង្ស័យថាជននេះមានសតិវិបល្លាសស្មារតី ក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដូច្នេះជនជាប់ចោទទាំងពីរនាក់នេះជាសមត្ថជនអាចពិចារណា និងយល់ដឹងអំពីព្យសនកម្មដែលកើតចេញពីអំពើរបស់ខ្លួន ហើយលក្ខខណ្ឌគតិយុត្តិតម្រូវឲ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងត្រូវបានច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ។

៥-ពិនិត្យលើសកម្មភាពជាក់ស្តែង បង្ហាញឲ្យឃើញនូវកត្តាផ្លូវចិត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ដារីត និងឈ្មោះ [redacted] ណារិន ពិតជាមានចេតនាលួចឆក់យកកាបូបពីជនរងគ្រោះប្រាកដមែន ពោលគឺព្យសនកម្មនេះ គឺជាបច្ច័យដែលកើតចេញពីចេតនាទុច្ចរិតរបស់ជនជាប់ចោទទាំងពីរនាក់នេះ ដែលមានបំណងយកទ្រព្យសម្បត្តិរបស់ជនរងគ្រោះមកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន។

៦-តាមកត្តាផ្លូវចិត្តដែលស្តែងចេញតាមរយៈសកម្មភាពរបស់ជនជាប់ចោទ និងចម្លើយសារភាពរបស់ជនជាប់ចោទ ឃើញថាមានការស៊ីសង្វាក់ទៅនឹងចម្លើយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ឃើញថាជនជាប់ចោទ ពិតជាបានប្រព្រឹត្តអំពើលួច(ឆក់កាបូប)របស់ជនរងគ្រោះប្រាកដមែន។

៧-អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម និងបំពានលើទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាកំណត់ថាជាអំពើលួច តាមមាត្រា៣៥៣ និងមាត្រា៣៥៦។

៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ។

៩-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ដារីត បានសុំឲ្យ



Scanned by CamScanner

តុលាការបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួន ដោយសារកូនក្តីខ្លួនអនីតិជន និងជាកូនកំព្រាដែលរស់នៅជាមួយជីដូនពុំទទួលបានការអប់រំបានត្រឹមត្រូវ ហើយកូនក្តីខ្លួនក៏បានឆ្លើយសារភាពនូវអំពើដែលខ្លួនបានប្រព្រឹត្តនោះ មានលក្ខណៈសមស្រប គប្បីតុលាការពិចារណាសម្រេចតាមច្បាប់។

១០-មានពិរុទ្ធភាពលើ៖

ក-ឈ្មោះ[redacted]ដាវីត ភេទប្រុស អាយុ១៥ឆ្នាំ

ខ-ឈ្មោះ[redacted]ណារិន ភេទប្រុស អាយុ២៦ឆ្នាំ

ពីបទលួច ប្រព្រឹត្តនៅនៅនៅចំណុចមុខផ្សារទំនើបឡាក់គី ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១១-តាមកំណត់ហេតុទទួលវត្ថុចាប់យក(១)លេខ២០៦រ.វ.ត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ វត្ថុចាប់យករួមមាន៖ ១-ម៉ូតូចំនួន០១គ្រឿង ម៉ាកនិច ពណ៌ស ស្លាកលេខ ភ្នំពេញ ១FK-៩៨៨៧។ ២-ទូរស័ព្ទម៉ាកណូគារចុចពិល០១គ្រឿង។ ឃើញថា វត្ថុចាប់យកមានម៉ូតូចំនួនមួយគ្រឿងនោះ ត្រូវបានចៅក្រមស៊ើបសួរសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញរួចហើយតាមដីកាសម្រេចលេខ៨៥១-ឆ-ព្រ.ទ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦។ ចំណែកវត្ថុចាប់យកទូរស័ព្ទម៉ាកណូគារចុចពិលមួយគ្រឿង គប្បីតុលាការសម្រេចតាមច្បាប់។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសលើជនជាប់ចោទ៖

ក-ឈ្មោះ [redacted]ដាវីត ភេទប្រុស អាយុ១៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល១០(ដប់)ខែ។

ខ-ឈ្មោះ[redacted]ណារិន ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០១(មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ។

ពីបទ លួច ប្រព្រឹត្តនៅនៅចំណុចមុខផ្សារទំនើបឡាក់គី ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុចាប់យករួមមានទូរស័ព្ទម៉ាកណូគារចុចពិល០១គ្រឿង តាមកំណត់ហេតុទទួលវត្ថុចាប់យក(១) លេខ២០៦រ.វ.ត ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូង និងអយ្យការ អមសាលា ដំបូងរាជធានីភ្នំពេញ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ ដោះ ដាវីត និងឈ្មោះ អេ ណារិន ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: |
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned by CamScanner